# របៀបសរសេរ របាយការណ៍

នាំមកជូនដោយៈ សង្គមនិងច្បាប់

# ឯកសារ

សម្រាប់

# ការសរសេររាយការណ៍

រៀបចំដោយ: លោក **អ៊ុន សំណាង**

មន្ត្រីរាយការណ៍អង្គការខុមហ្វ្រែល

ដកស្រង់ពីឯកសារវគ្គបណ្តុះបណ្តាលស្តីពីការរាយការណ៍របស់ VBNK

# មាតិកា


និយមន័យនៃពាក្យគន្លឹះខ្លះៗសម្រាប់ការសរសេររបាយការណ៍ ........ 4

គោលដៅនៃការបង្ហាញ ........ Error! Bookmark not defined.

គោលបំណងនៃបទបង្ហាញ ........ Error! Bookmark not defined.

ផ្នែកទី១ កិច្ចពិភាក្សាមុនបទបង្ហាញ ........ 1

កិច្ចពិភាក្សាតាមក្រុម ........ 1

ផ្នែកទី២: គោលបំណង ដំណើរការ លក្ខណៈ និងទំរង់នៃរបាយការណ៍ ........ 3

សេចក្តីផ្តើម ........ 3

គោលបំណង ........ 3

សំណួរបំផុសគំនិត ........ 4

សំណួរពិភាក្សាតាមក្រុម ........ 5

លំហាត់អនុវត្ត ១ ........ 9

លំហាត់អនុវត្ត ២ ........ 11

ផ្នែកទី៣: ការអនុវត្តសរសេរកំណត់ហេតុ ........ 14

សេក្តីផ្តើម ........ 14

គោលបំណងនៃមេរៀននេះ ........ 14

ការសំដែង ........ 14

កំណត់ត្រាល្អ ........ 15

ការណែនាំ: ការធ្វើកំណត់ហេតុនៃកិច្ចប្រជុំ ........ 16

គំរូនៃការធ្វើកំណត់ហេតុពេលប្រជុំ ........ 18

ផ្នែកទី៤ ការសង្ខេបព័ត៌មាន ........ 19

សេចក្តីផ្តើម ........ 19

គោលបំណង ........ 19

គោលការណ៍នៃការសង្ខេបព័ត៌មាន ........ 19

ឧទាហរណ៍៖ ........ 21

សំណួរពិភាក្សា ........ 21

លំហាត់អនុវត្ត១ ........ 23

លំហាត់អនុវត្ត២ សង្ខេបព័ត៌មានខាងក្រោម ........ 24

ផ្នែកទី៥: ការសរសេរសេចក្តីផ្តើម និងការសន្និដ្ឋាន ........ 26

សេចក្តីផ្តើម ........ 26

គោលបំណង ........ 26

ការពិភាក្សា ........ 26

ការពិភាក្សាតាមក្រុម ........ 28

គោលការណ៍ណែនាំអំពីការសរសេរសេចក្តីផ្តើមនៃរបាយការណ៍: ........ 28

ការពិភាក្សាជាក្រុម ........ **Error! Bookmark not defined.**

គោលការណ៍ណែនាំអំពីការសរសេរសេចក្តីសន្និដ្ឋាន ........ 29

## និយមន័យនៃពាក្យគន្លឹះខ្លះៗសម្រាប់ការសរសេររបាយការណ៍

**របាយការណ៍:** ជាខ្លឹមសារដែលត្រូវបានសរសេរទៅតាមលំដាប់លំដោយ និងមានលក្ខណៈមិនចំពោះ ប្រើសម្រាប់ពាំនាំព័ត៌មាន ពីតំបន់ការងារមួយទៅតំបន់ការងារមួយទៀតរបស់អង្គការ ឬពីស្ថាប័នមួយទៅស្ថាប័នមួយទៀត ក្នុងន័យរួមចំណែកក្នុងការសម្រេចចិត្ត ឬដោះស្រាយបញ្ហា ។

**ឯកសារ:** ក្រដាសស្នាមដែលផ្តល់ព័ត៌មាន ព្រឹត្តិការណ៍ពិត តថភាព អ្វីៗដែលបានកើតឡើងពិតប្រាកដ ឬកំពុងកើតឡើង ។ អ្វីៗដែលគេទទួលស្គាល់ ឬទទួលយកថាពិតជាក់ស្តែង ។

**យោបល់:** ជាអ្វីដែលមនុស្សគិតអំពី ដោយផ្អែកលើការសម្រេច ថ្លឹងថ្លែង កាត់ក្តីផ្ទាល់ខ្លួនជាជាងការពិតជាក់ស្តែង ។

**កំណត់ហេតុ:** ការកត់ត្រាជាផ្លូវការដែលអធិប្បាយពីអ្វីមួយមាននៅក្នុងអង្គប្រជុំ និងការសម្រេចត្រូវបានប្រកាន់យក ។

**សង្ខេប:** ជាការរៀបរាប់ខ្លីៗស្តីពីចំណុចសំខាន់ៗ

**សន្និដ្ឋាន:** ជាទីបញ្ចប់នៃអត្ថបទណាមួយ ជាការវាយតម្លៃ ជាការសម្រេចដែលប្រកាន់យក ក្រោយពីបានគិតគូរពិចារណា

**អនុសាសន៍:** ជាការផ្តល់ដំបូន្មាន ឬសំណូមពរណាមួយ ឬជាការផ្តល់ព័ត៌មានសរសើរអំពីអ្វីមួយ

**បែបបទ ឬរចនា:** ជាការជ្រើសរើសពាក្យ ឬរបៀបសរសេរដែលប្រើប្រាស់ដោយអ្នកនិពន្ធ អ្នកសរ-សេរ

**ទំរង់ រចនាសម្ព័ន្ធ:** ជាការចាត់ចែង រៀបចំមួយដែលផ្នែកទាំងឡាយត្រូវបានផ្គុំបញ្ចូលគ្នាឡើង

## គោលដៅនៃការបង្ហាញ

ការបង្ហាញនេះនឹងជួយផ្តល់ដល់អ្នកចូលរួមនូវចំណេះដឹង និងបទពិសោធន៍ការងារពាក់ព័ន្ធនឹងការសរសេររបាយការណ៍ ។

## គោលបំណងនៃបទបង្ហាញ

នៅចុងបញ្ចប់នៃការបង្ហាញ អ្នកចូលរួមនឹងៈ

- យល់ដឹងពីវត្ថុបំណងនៃឯកសារនានាក្នុងអង្គការ
- អាចបង្ហាញព័ត៌មានទៅតាមទំរង់ខុសៗគ្នា
- ទទួលបទពិសោធន៍ក្នុងការបង្កើតឯកសារនានាទៅតាមទំរង់នោះ
- មានការយល់ដឹងអំពីលក្ខណៈនៃរបាយការណ៍

## ផ្នែកទី១ កិច្ចពិភាក្សាមុនបទបង្ហាញ

### កិច្ចពិភាក្សាតាមក្រុម

១. ពេលអ្នកសរសេររបាយការណ៍ ឬលិខិតស្នាមនានារួចហើយ តើអ្នកធ្វើអ្វីទៀត? តើអ្នកធ្លាប់សុំឲ្យសហសេវិកអ្នកជួយអាន ដែរឬទេ?

២.បើធ្លាប់ តើគេធ្វើអ្វីខ្លះបន្ទាប់ពីអានលិខិតនោះហើយ?

៣.តើមានគោលការណ៍សំខាន់ៗអ្វីខ្លះក្នុងការផ្តល់ចម្លើយតបក្នុងន័យស្ថាបនា?

៤. តើអ្នកត្រូវគិតពីចំណុចអ្វីខ្លះពេលសរសេររបាយការណ៍ដើម្បីឲ្យរបាយការណ៍នោះមានលក្ខណៈប្រសើរឡើង ?

**ចម្លើយចូលរួម: គោលការណ៍ក្នុងការផ្តល់ការរិះគន់ក្នុងន័យស្ថាបនា**

អ្នកត្រូវចាំថាវត្ថុបំណងក្នុងការធ្វើបែបនេះ គឺជួយគ្នាទៅវិញទៅមក ។ ការរិះគន់ក្នុងន័យស្ថាបនាត្រូវតែមានប្រយោជន៍ និងមិនបន្ទុះបង្អាប់ ពន្យល់ឲ្យបានច្បាស់ពីអ្វីដែលអ្នកបានគិត ។ ឧទាហរណ៍ "ខ្ញុំមិនយល់ពីអត្ថន័យរបស់ឃ្លានេះទេ គេអាចយល់ថាវាមានន័យច្រើន" ។ ឃ្លានេះវានឹងច្បាស់ជាងនេះ បើយើងបញ្ជាក់បន្ថែមចំណុចនេះ វាមានភាពប្រសើរជាងចំពោះពាក្យដែលថា "ចំណុចនេះមិនល្អទេ" ។

កុំនិយាយប្រាប់អ្នកណាម្នាក់នូវអ្វីដែលបានផ្លាស់ប្តូរ ។ ជួយពួកគេជ្រើសរើសចម្លើយដោយខ្លួនឯង ។ ឧទាហរណ៍ កុំនិយាយថា "អ្នកត្រូវបន្ថែមឃ្លានេះដោយ...." និងផ្តល់ពាក្យឬគំនិតរបស់អ្នក ។ វាជាការល្អគួរបង្ហាញចំណុចដែលត្រូវផ្លាស់ប្តូរដោយនិយាយថា "អ្នកគិតថាធ្វើបែបនេះ ឬបែបនោះ...." ។ កុំផ្តោតការយកចិត្តទុកដាក់ទៅលើភាពមិនចុះសម្រុងគ្នាលើចំណុចជាអវិជ្ជមាន ។ ចូរចងចាំថាត្រូវលើកសរសើរអ្វីដែលល្អផង ។ ឧ.ជាទូទៅខ្ញុំគិតថារបាយការណ៍នេះមានសារសំខាន់ ហើយវាផ្តល់នូវព័ត៌មានច្បាស់លាស់ ។ ប៉ុន្តែ ខ្ញុំយល់ថានូវមានចំណុចពីរគួរបញ្ជាក់បន្ថែម ដើម្បីឲ្យរបាយការណ៍នេះកាន់តែប្រសើរថែមទៀត ។

បើនរណាម្នាក់ព្យាយាមបញ្ជាក់ពីចំណុចណាមួយ ចូរអនុញ្ញាតឲ្យគេធ្វើចុះ ដោយចាត់ទុកអ្នកថាជាអ្នកស្ដាប់គំនិតរបស់គេ ។ វាមានសារៈសំខាន់ណាស់ក្នុងការផ្ដល់ឱកាសដល់នរណាម្នាក់ឲ្យគិតដោយខ្លួនគេជាជាងប្រាប់ពួកគេពីអ្វីដែលត្រូវធ្វើ ។ ចូរចងចាំថានៅពេលក្រោយ បុគ្គលនេះអាចផ្ដល់ការឆ្លើយតបដល់អ្នកអំពីការងាររបស់អ្នកវិញ ។

**តើអ្នកត្រូវគិតពីចំណុចអ្វីខ្លះពេលសរសេររបាយការណ៍ដើម្បីឲ្យរបាយការណ៍នោះមានលក្ខណៈប្រសើរឡើង ?**

គោលការណ៍ខ្លះៗ ដែលជាមូលដ្ឋានដើម្បីធ្វើឲ្យការសរសេរទៅជាទំរង់មួយនៃការប្រាស្រ័យទាក់ទងបានល្អ ។

- សម្រេចយកបែបបទ និងទំរង់ណាដែលសមស្របទៅនឹងគោលបំណងរបស់ឯកសារ
- សរសេរដោយប្រើភាសាសាមញ្ញ ច្បាស់ៗ កុំព្យាយាមប្រើពាក្យលំបាកៗ (ពាក្យវប្បធម៌)
- សរសេរដោយផ្ដោតលើប្រធានបទ ។ កុំនិយាយចូលរឿងផ្សេងទៀត (កុំចាកប្រធាន)
- ត្រូវរៀបចំឯកសារឲ្យបានល្អ ដោយដាក់ព័ត៌មានទៅតាមលំដាប់លំដោយ ។ កុំផ្លោះពីនេះទៅនោះ និងត្រឡប់ក្រោយម្ដងទៀត ។
- សរសេរឲ្យបានច្បាស់ហើយខ្លីៗ ។ នេះមានន័យថាអ្នកត្រូវប្រាកដក្នុងចិត្តនូវអ្វីដែលអ្នកចង់និយាយ និងពេលណាដែលអ្នកនិយាយរឿងនោះ និងនិយាយដោយខ្លីៗតាមលទ្ធភាពដែលអាចធ្វើទៅបាន ។
- ត្រូវមានភាពជាក់លាក់នូវអ្វីដែលបានបញ្ជាក់ ។ ផ្ដល់សេចក្ដីលំអិត និងការពន្យល់ពិតប្រាកដ មិនពាសវាលពាសកាល ។
- ចៀងវាងភាពច្រំដែល
- ចៀសវាងការសម្រេច ថ្លឹងថ្លែង កាត់ក្ដីផ្ទាល់ខ្លួនដែលមិនសមស្រប
- ត្រូវប្រាកដថា អ្នកអានមិនអាចយល់អត្ថបទបច្ចេកទេស បើសិនជាគ្មានការពន្យល់ ។
- ផ្ដល់ពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំឯកសារតាមសំរួល
- កំណត់ពេលវេលាដើម្បីបញ្ចប់ការងារ បើសិនជាអាច
- អានឯកសារម្ដងទៀតដោយកែសម្រួលផង មុននឹងបញ្ជើយឯកសារនោះ ។
- កត់ត្រាជានិច្ចនៅកន្លែងណាមួយក្នុងឯកសារថា នរណាជាអ្នកសរសេរ និងមុខងាររបស់គេហើយនៅពេលណា ។
- ត្រូវប្រាកដថាគេអាចមើលឯកសារនេះយល់ ។ វាគ្មានប្រយោជន៍អ្វីទេក្នុងការរៀបចំឯកសារឲ្យបានល្អ បើសិនជាអ្នកទទួលមើលមិនយល់ ។

## ផ្នែកទី២: គោលបំណង ដំណើរការ លក្ខណៈ និងទំរង់នៃរបាយការណ៍

### សេចក្តីផ្តើម

ដើម្បីសរសេររបាយការណ៍មួយឲ្យបានល្អ យើងត្រូវតែដឹងថា ហេតុអ្វីជាយើងចង់សរសេររបាយការណ៍នោះ ហើយតើត្រូវធ្វើដូចម្តេច ដើម្បីឲ្យការសរសេរនោះមានប្រសិទ្ធភាព ។ដូច្នេះយើងត្រូវដាក់បញ្ចូលនូវព័ត៌មានមួយចំនួនដែលទាក់ទងនឹងរបាយការណ៍នោះ ហើយកាត់ចោលនូវព័ត៌មានមួយចំនួនដែលមិនបានការ ។ មុននឹងសរសេរយើងត្រូវពិចារណានូវសំណួរមួយចំនួន បន្ទាប់មកត្រូវប្រមូលព័ត៌មាននិងស្វែងរកការពិតទាំងឡាយណាដែលអាចរកបាន ហើយទាញយកសេចក្តីសន្និដ្ឋានណាមួយដែលងាយយល់ ។

### គោលបំណង

នៅចុងបញ្ចប់នៃផ្នែកនេះ អ្នកចូលរួមនឹង:

- មានការយល់ដឹងអំពីលក្ខណៈនៃរបាយការណ៍
- បានកំណត់អំពីគោលបំណង ទំរង់ ឬរចនាសម្ព័ន្ធ និងដំណើរការនៃការសរសេររបាយការណ៍
- ទទួលចំណេះដឹងអំពីអ្វីដែលត្រូវបញ្ចូល និងអ្វីដែលត្រូវកាត់ចេញនៅពេលដែលយើងសរសេររបាយការណ៍
- ទទួលបានចំណេះដឹងពីរបៀបសរសេរកំណត់ហេតុ សង្ខេបព័ត៌មាន និងសេចក្តីផ្តើម និងសេចក្តីសន្និដ្ឋាន

## សំណួរបំផុសគំនិត

១. តើរបាយការណ៍មានអត្ថន័យដូចម្តេច?

២. យោលទៅលើបទពិសោធន៍របស់អ្នក តើរបាយការណ៍មានប៉ុន្មានប្រភេទ ហើយមានមុខងារអ្វីខ្លះ?

៣. តើការសរសេររបាយការណ៍ប្រព្រឹត្តិទៅដូចម្តេច?

៤. តើគោលបំណងនៃការសរសេររបាយការណ៍មានអ្វីខ្លះ?

**ចម្លើយចូលរួម**

១. របាយការណ៍ជាខ្លឹមសារដែលត្រូវបានគេសរសេរទៅតាមលំដាប់លំដោយនិងមានលក្ខណៈមិនចំពោះ ប្រើសម្រាប់នាំនាំព័ត៌មានពីតំបន់ការងារមួយទៅតំបន់ការងារមួយទៀតរបស់អង្គការ ឬពីស្ថាប័នមួយទៅស្ថាប័នមួយទៀត ក្នុងន័យរួមចំណែកក្នុងការសម្រេចចិត្តឬដោះស្រាយបញ្ហា ។

**២. ប្រភេទនៃរបាយការណ៍ និងមុខងាររបស់វា**

គេឃើញមានរបាយការណ៍ពីរប្រភេទដែលអាចជារបៀបផ្តល់ព័ត៌មានឬជារបៀបស៊ើបអង្កេតស្រាវជ្រាវ ។

- ✓ ***របាយការណ៍ជាប្រចាំឬរបាយការណ៍ក្នុងដំណាក់កាលជាក់លាក់ណាមួយ៖*** របាយការណ៍នេះ ត្រូវបានគេសរសេរជាទៀងទាត់ ។ ន.របាយការណ៍ប្រចាំខែ របាយការណ៍វិវត្តន៍ របាយការណ៍ប្រចាំត្រីមាស.......(មានទំរង់គំរូ ជារបៀបបង្ហាញព័ត៌មាន)
- ✓ ***របាយការណ៍តាមការស្នើសុំ ឬរបាយការណ៍ស្រាវជ្រាវ៖*** ជារបាយការណ៍ដែលគេសរសេរតែម្តងគត់ និងមានគោលបំណងជាក់លាក់ ។ វាទាមទារឲ្យមានការស្រាវជ្រាវនិងការស៊ើបអង្កេតក្នុងករណីខ្លះដូចជា: ការជម្លៀសចេញដោយ ការសន្និដ្ឋាន និងមានអនុសាសន៍ បើសិនជាអ្នកអានចង់បាន

**៣.ដំណើរការនៃការសរសេររបាយការណ៍**

- .កំណត់គោលបំណង (សម្រាប់អ្នកណា? គេចង់ដឹងអំពីអ្វី? កាលបរិច្ឆេទកំណត់?...)
- ការប្រមូលព័ត៌មាន
- ការវិភាគព័ត៌មាន

- រៀបព័ត៌មានតាមលំដាប់លំដោយ
- ច្រោះយកចំណុចសំខាន់ៗ និងកាត់ចោលអ្វីដែលមិនសំខាន់
- ធ្វើពង្រាងរបាយការណ៍ពីកំណត់សំគាល់របស់អ្នក
- អានឡើងវិញ កែសំរួល អានជាចុងក្រោយ
- ការសម្រេចចុងក្រោយ

៥. គោលបំណងក្នុងការសរសេររបាយការណ៍

- រក្សាជាកំណត់ត្រា និងទុកជាភស្តុតាង
- ចែករំលែកព័ត៌មានដល់អ្នកដទៃ ពេលខ្លះដល់កន្លែងផ្សេងទៀត
- ដើម្បីមានទំរង់បែបបទជាទៀងទាត់មួយសម្រាប់ឲ្យអ្នកផ្សេងទៀតអនុវត្តតាម
- ជូនកាលព័ត៌មានច្រើនពេក គេមិនអាចចងចាំបានច្រើន
- ធ្វើឲ្យមានព័ត៌មានគ្រប់គ្រាន់ពេលណាត្រូវការ
- ធ្វើឲ្យរឿងណាមួយមានលក្ខណៈផ្លូវការ
- ផ្តល់ព័ត៌មានដូចៗគ្នាសម្រាប់ក្រុមមនុស្សច្រើន
- នៅពេលដែលរបាយការណ៍គឺជាផ្នែកមួយនៃការប្រាស្រ័យទាក់ទងគ្នាបាន

## សំណួរពិភាក្សាតាមក្រុម

ក.តើសំណួរអ្វីខ្លះដែលត្រូវពិចារណា មុនពេលចាប់ផ្តើមសរសេររបាយការណ៍?

ខ.តើអាចមានប្រភពព័ត៌មានពីអ្វីខ្លះសម្រាប់សរសេររបាយការណ៍?

គ. តើព័ត៌មានអ្វីខ្លះដែលអ្នកសម្រេចថាគួរតែដាក់បញ្ចូល និងអ្វីខ្លះដែលអ្នកគិតថាមិនគួរដាក់បញ្ចូល?

ឃ.តើរបាយការណ៍មានលក្ខណៈដូចម្តេច?

ង. តើរបាយការណ៍មានទំរង់អ្វីខ្លះ?

### ចម្លើយចូលរួម

**ក. សំណួរសំខាន់ៗដើម្បីពិចារណាមុនពេលសរសេររបាយការណ៍ មានដូចជា**

- **ហេតុអ្វី:** ហេតុអ្វីបានជាយើងចាំបាច់សរសេររបាយការណ៍នេះ? តើរបាយការណ៍នេះមានគោលបំណងដូចម្តេច? និងប្រើប្រាស់ដូចម្តេច?

- **តើឯកសារនេះធ្វើឡើងសម្រាប់អ្នកណា?** តើវាជាឯកសារសម្រាប់ប្រើប្រាស់ផ្ទៃក្នុងអង្គការ ឬត្រូវផ្សព្វផ្សាយទៅខាងក្រៅ? (ឧ.របាយការណ៍ប្រចាំឆ្នាំ) តើអ្នកអានអាចមានលទ្ធភាពយល់ខ្លឹមសារបានប៉ុណ្ណា? បើសិនអ្នកសរសេររបាយការណ៍មួយអំពីបញ្ហាណាមួយជាក់លាក់សម្រាប់អ្នកគ្រប់គ្រងរបស់អ្នក តើគាត់ចង់ចែករំលែកព័ត៌មាននេះទៅអ្នកផ្សេងទៀតដែរឬទេ? តើគេចង់បានការពិតច្រើន ឬគេចង់បានមតិយោបល់របស់យើង?
- តើបែបបទណាដែលសមស្របសំរាប់ឯកសារនេះ?
- ឯកសារនេះមានទំរង់ជាគំរូដែរឬទេ? តើមានការណែនាំណាមួយដែរឬទេ ចំពោះការរៀបព័ត៌មានឲ្យត្រូវក្នុងឯកសារនេះ?

## ខ.ប្រភពព័ត៌មាន

- លិខិតទំនាក់ទំនងទៅវិញទៅមក
- របាយការណ៍លើកមុន
- ការពិត
- ការកត់ត្រាអំពីការប្រជុំ ឬសិក្ខាសាលាណាមួយ
- សកម្មភាពបានធ្វើរួចហើយ
- ការសម្រេចចេញពីកិច្ចពិភាក្សា
- សំណើផែនការ

## គ. តើត្រូវសរសេរអ្វីខ្លះ?

✓ គោលបំណងរបស់ឯកសារ "តើអ្នកអានចង់ដឹងអំពីអ្វី?"
✓ ព័ត៌មានត្រួសៗឬលំអិត
✓ ព័ត៌មានថ្មីៗ
✓ ព័ត៌មានដែលពាក់ព័ន្ធ
✓ ការពិតនិងភស្តុតាង

**តើមិនត្រូវសរសេរអ្វីខ្លះ?**

- ភាពលំអិតដែលគ្មានប្រយោជន៍
- ពាក្យទាំងឡាយដែលអ្នកអានមិនយល់
- សរសេររៀបរាប់វែងអន្លាយ

### ឃ. តើរបាយការណ៍មានលក្ខណៈដូចម្ដេច?

- ត្រូវសរសេរទៅថ្នាក់លើ
- ត្រូវរៀបចំតាមលំដាប់លំដោយ
- មានលក្ខណៈមិនលំអៀង
- ត្រូវកំណត់អ្នកអានឲ្យបានជាក់លាក់

**ង. ទំរង់នៃរបាយការណ៍:** ទំរង់នៃរបាយការណ៍ អាស្រ័យនឹងគោលបំណងនៃរបាយការណ៍ និងតំរូវការចាំបាច់នៃភាពផ្លូវការ ។ ទោះជាយ៉ាងណាក៏ដោយ វាអាចមានគំរូមួយ ។

**ទំរង់របាយការណ៍មិនផ្លូវការ**មួយអាចមានបីផ្នែក:

- ***សេចក្ដីផ្ដើម:*** លំនាំនៃស្ថានភាព ហេតុផលផ្សេងៗក្នុងការសរសេររបាយការណ៍ អ្នកណាត្រូវការ? តើគេមើលទៅលើអ្វី?
- ***តួសេចក្ដី:*** បង្ហាញព័ត៌មាន ការពិតនិងប្រភពរបស់ព័ត៌មាន ចំណងជើងលេខរៀងអាចប្រើប្រាស់ដើម្បីចែកឲ្យដាច់ចំណុចផ្សេងៗនៃព័ត៌មាន ។
- ***ការសន្និដ្ឋាន:*** ការសេរុបព័ត៌មានឡើងវិញ ។ អនុសាសន៍អាចសរសេរនៅទីនេះតែត្រូវពឹងផ្អែកលើការពិតខាងលើ ។

**របាយការណ៍ផ្លូវការ**មួយមានលក្ខណៈមំត់ចត់ជាងរបាយការណ៍មិនផ្លូវការ ។ ជូនកាលដោយផ្អែកលើការស្រាវជ្រាវ ការពិនិត្យមើលលើបញ្ហាណាមួយ ។ ជាលទ្ធផលរបាយការណ៍ផ្លូវការមួយអាចមានច្រើនផ្នែក ដូចជាចំណងជើង លិខិតព្រមព្រៀងការងារ សេចក្ដីផ្ដើម លទ្ធផល សន្និដ្ឋាន ។ យ៉ាងណាក៏ដោយអង្គការនីមួយៗចូលចិត្តទំរង់ខុសៗគ្នា ។

**ចំណែកផ្សេងៗនៃរបាយការណ៍ផ្លូវការណ៍**

ចំពោះរបាយការណ៍ផ្លូវការខ្លះអាចមានចំណែកសំខាន់ៗដូចជា៖

- លិខិតបញ្ជូន
- ទំព័រចំណងជើង
- មាតិកា
- ការសង្ខេប

- សេចក្ដីផ្ដើម
- តួរបាយការណ៍
- ការសង្ខេបចុងក្រោយ ឬការសន្និដ្ឋាន
- អនុសាសន៍
- ឯកសារភ្ជាប់
- ឯកសារយោង

- **លិខិតបញ្ជូន:** លិខិតនេះធ្វើឡើងសម្រាប់មនុស្សឬ អង្គភាពដែលត្រូវទទួលរបាយការណ៍នេះ
- **ទំព័រចំណងជើង:** ទំព័រមុខគេដែលបង្ហាញពីអ្នកសរសេររបាយការណ៍ កាលបរិច្ឆេទ អ្នកទទួលឬអង្គភាពដែលទទួលរបាយការណ៍
- **មាតិកា:** បង្ហាញពីខ្លឹមសារជាក់លាក់ ហើយរៀបរាប់ពីលេខរៀងចំណងជើង និងលេខទំព័រ
- **ការសង្ខេប:** បង្ហាញពីការសង្ខេបនៃរបាយការណ៍ស្រេចបាច់មួយឲ្យនៅត្រឹមមួយទំព័រឬតិចជាងនេះដែលមាន៖
  - គោលបំណង
  - បញ្ហាដែលត្រូវដោះស្រាយ
  - ដំណោះស្រាយដែលគួរពិចារណា
  - ដំណោះស្រាយដែលត្រូវជ្រើសរើស
  - សកម្មភាពដែលស្នើឡើង
- **សេចក្ដីផ្ដើម:** គោលបំណងនៃសេចក្ដីផ្ដើមគឺ៖
  - ពន្យល់ពីគោលបំណងរបស់របាយការណ៍
  - លំនាំដើមនៃបញ្ហានិងភាពសំខាន់នៃដំណោះស្រាយ
  - ពន្យល់អ្នកអានពីផែនការ និងទិដ្ឋភាពផ្សេងៗដែលត្រូវដោះស្រាយ
  - ការកំណត់ប្រភពព័ត៌មាន និងវិធីសាស្ត្រ
- **តួរបាយការណ៍:** ជាចំណែកមួយនៃរបាយការណ៍ដែលមានព័ត៌មានពាក់ព័ន្ធ និងត្រូវតាមលំដាប់លំដោយ ។
- **ការសង្ខេបចុងក្រោយ ឬសេចក្ដីសន្និដ្ឋាន:** គឺជាការសំរេចចិត្តក្នុងការបញ្ចេញជាមតិគំនិតយោបល់ ឬសំណើរបែបជាអនុសាសន៍អំពីរឿងអ្វីមួយបន្ទាប់ពីបានពិនិត្យពិចារណាលើគល់គ្រប់ព័ត៌មានទាំងអស់រួចមក ។

- **ឯកសារយោង:** រៀបរាប់ពីប្រភពឯកសារដែលប្រើប្រាស់ ។ ចំណែកនេះគេរៀបចំតាមលំដាប់លំដោយអក្សរ ឬតាមឈ្មោះអ្នកនិពន្ធ រួមមាន: កាលបរិច្ឆេទបោះពុម្ព ចំណងជើងសៀវភៅ ទីកន្លែងបោះពុម្ព និងឈ្មោះក្រុមហ៊ុន ។
- **ឯកសារភ្ជាប់:** បង្ហាញពីសេចក្ដីបន្ថែមមិនសូវសំខាន់តែពាក់ព័ន្ធនឹងបញ្ហា ។

## លំហាត់អនុវត្ត ១

ក.ចូរអានរបាយការណ៍ខាងក្រោមនេះ ហើយឆ្លើយនឹងសំណួរ: តើទំរង់នៃរបាយការណ៍មានអ្វីខ្លះ?

ខ. ចូរផ្ទៀងផ្ទាត់ផ្នែកនីមួយៗនៃរបាយការណ៍ផ្លូវការ ទៅនឹងលេខដែលមានការអធិប្បាយខាងក្រោម ហើយដាក់ពាក្យត្រូវតាមលំដាប់លំដោយ ។

ក. ជំរាបជូនទៅ:...... ប្រធានផ្នែកធនធាន

មកពី: ...................

ថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១២

**របាយការណ៍ស្ដីពីការបង្ការភាពខ្ជះខ្ជាយលើការប្រើប្រាស់សំភារៈការិយាល័យ**

សេចក្ដីផ្ដើម

កាលពីថ្ងៃទី ០១ ខែមីនាឆ្នាំ២០១២ លោកប្រធានបានឲ្យខ្ញុំស៊ើបអង្កេតលើកំណើននៃការប្រើប្រាស់សំភារៈការិយាល័យនៅផ្នែកនេះ និងរកឲ្យឃើញនូវវិធីដើម្បីឲ្យការប្រើប្រាស់មានលក្ខណៈសន្សំសំចៃជាងនេះ ។ ខ្ញុំបានស៊ើបអង្កេត ដោយពិភាក្សាជាមួយបុគ្គលិកផ្នែកនេះទាំងកំរិតអ្នកគ្រប់គ្រងនិងស្មៀន ។ ខ្ញុំបានពិនិត្យបញ្ជីចេញចូលនៃសំភារៈការិយាល័យដោយប្រៀបធៀបការប្រើប្រាស់ឆ្នាំនេះទៅនឹងឆ្នាំមុន ។

ព័ត៌មានដែលរកឃើញ

ដោយយោងតាមយោបល់ ហេតុផលរបស់បុគ្គលិកចំពោះកំណើននេះគឺ:

1. ក្រដាសដែលមានរូបសញ្ញាអង្គភាព ត្រូវបានប្រធានប្រើប្រាស់ជាក្រដាសព្រៀង
2. ទូសំភារៈការិយាល័យមិនដែលចាក់សោរទេ ដូច្នេះបុគ្គលិកគិតថាមិនមានការផែកនេះទេ គេអាចយកប្រើតាមចិត្ត
3. សំបុត្រដែលផ្ញើ ទោះបីជាប្រើប្រាស់នៅក្នុង និងមិនមានការសំខាន់ក៏ដោយ ក៏គេត្រូវប្រើស្រោមសំបុត្រសដែរ

4. នៅក្នុងអង្គភាពមិនដែលមានអ្នកណាប្រើស្រោមសំបុត្រមួយជាលើកទីពីរទេ
5. ម៉ាស៊ីនកូពីកើតមានកំហុសជាដដែលៗចំពោះការដាប់ក្រដាសជាច្រើនលើក ជាលទ្ធផលមានបរិមាណក្រដាសត្រូវប្រើលើសចំណុះ

**ការពិនិត្យមើលបញ្ជីចេញចូលបានបង្ហាញថា:**

- ថ្លៃសម្ភារៈសម្រាប់ត្រីមាសទី១នេះ មានកំណើន២៥ភាគរយបើធៀបនឹងឆ្នាំមុន
- កំណើត១០ភាគរយជាមធ្យម បើប្រៀបធៀបនឹងឆ្នាំមុន

**សន្និដ្ឋាន**

ការស៊ើបអង្កេតបានបង្ហាញថាកំណើននៃការប្រើប្រាស់សម្ភារៈការិយាល័យដោយសារភាពខ្ជះខ្ជាយពេញទាំងផ្នែកនេះ ។

**ខ្ញុំស្នើឲ្យមានវិធានការណ៍មួយចំនួនដើម្បីកែលំអស្ថានការណ៍:**

- លើកយករឿងនេះដាក់ជារបៀបវារៈនៅពេលប្រជុំ ដើម្បីរំលឹកបុគ្គលិកគិតពីកម្មវិធីព័ត៌មានវិទ្យា និងការប្រើប្រាស់ក្រដាសជាលើកទី២បើសិនជាអាចទៅរួច
- ការបញ្ចេញសម្ភារៈត្រូវត្រួតពិនិត្យដោយអ្នកកាន់សោរដែលជាអ្នកគ្រប់គ្រងផ្ទាល់
- គួរមានការពិចារណាលើការព្រមព្រៀងជាមួយអ្នកថែទាំម៉ាស៊ីនកូពី

## លំហាត់អនុវត្ត ២

ចូរផ្គូរផ្គងចំណែកផ្សេងៗនៃរបាយការណ៍ ជាមួយនឹងការរៀបរាប់ខាងក្រោម:

A. ទំព័រចំណងជើង

B. សង្ខេប

C. ឯកសារយោង

D. សៀវភៅប្រើប្រាស់ក្នុងការស្រាវជ្រាវ

E. លទ្ធផលការស្រាវជ្រាវ

F. ឯកសារភ្ជាប់

G. សេចក្តីថ្លែងការណ៍ (អំណរគុណ)

H. សន្និដ្ឋាន

I. សេចក្តីផ្តើម

J. អនុសាសន៍

K. មាតិកា

1. ចំណែកនេះអ្នកត្រូវបង្ហាញគំនិតចំពោះសកម្មភាពដែលអាចប្រកាន់យក ។ អ្នកអាចឲ្យជាដំណោះស្រាយចំពោះបញ្ហា ឬការឆ្លើយតបនឹងតម្រូវការរបស់លិខិតព្រមព្រៀងការងារ (Term of reference) ។ អ្នកអាចបញ្ចុះបញ្ចូលអ្នកអានថាអ្វីដែលអ្នកបានស្នើមានសារៈសំខាន់និងអាចអនុវត្តបាន ។ បើសិនជាសំណើនោះមានច្រើន សូមដាក់ឲ្យជាចំពីគ្នា ។
2. ផ្នែកនេះ រួមមានចំណែកទាំងអស់នៃរបាយការណ៍តាមលំដាប់លំដោយដោយមានបញ្ជាក់ទំព័រផង ។
3. ចំណែកនេះប្រាប់ដល់អ្នកអានពីអ្វីដែលអ្នកបាននិយាយ ។ ចំណែកនេះសរុបព័ត៌មានសំខាន់ៗដែលមាននៅក្នុងរបាយការណ៍ ។ អ្នកអាចពិចារណាពីគស្តុតាងដែលបានបង្ហាញនៅក្នុងតួនៃរបាយការណ៍ ។ ទីនេះអ្នកបង្ហាញយោបល់ផ្ទាល់ខ្លួនដោយផ្អែកលើការវិភាគព័ត៌មាន ។
4. ចំណែកនេះជាការនិយាយត្រួសៗនៃខ្លឹមសារទាំងមូលនៃតួរបាយការណ៍រួមមានអនុសាសន៍ផងដែរ ។ ចំណែកនេះមានសារៈសំខាន់ជាងគេនៅក្នុងរបាយការណ៍ ។ វាជាចំណែកមួយដែលគេអានដោយយកចិត្តទុកដាក់ជាពិសេសចំពោះអ្នកដែលមានការងារធ្វើច្រើន ។ ផ្នែកនេះត្រូវមានន័យទូលំទូលាយនិងហ្មត់ចត់ ។

5. ចំណែកនេះបង្ហាញប្រភពព័ត៌មានដែលអ្នកបានរកទិន្នន័យ ។ វាអាចជាគ្រឹះស្ថានរាប់ការសន្និដ្ឋាននិងអនុសាសន៍របស់អ្នក ។
6. ចំណែកនេះមានមុខងារសំខាន់ពីរ:
   - ជាកន្លែងសម្រាប់ពត៌មានបន្ថែម ។ ព័ត៌មាននេះមិនចាំបាច់សម្រាប់ការរកឃើញជាចំបងទេតែវាជួយគាំទ្រគំនិតក្នុងការវិភាគ ។ អ្នកអានអាចមើលគំនិតនេះប្រសិនបើគេចង់អាន ប៉ុន្តែការសរសេររបាយការណ៍អាចមានគ្រប់គ្រាន់ដោយមិនចាំបាច់មានផ្នែកនេះទេ ។
   - ជាកន្លែងបន្ថែមព័ត៌មានតាមក្រោយដោយមិនចាំបាច់សរសេរសាជាថ្មីម្តងទៀត ។ វាអាចបន្ថែមផងដែរនូវសន្ទានុក្រមនៃពាក្យបច្ចេកទេស និងសរសេរពាក្យបញ្ជីពាក្យបំព្រួញដើម្បីជួយអ្នកអាន ។
7. ផ្នែកនេះគឺសរសេរនូវបញ្ជីសំភារៈដែលមិនត្រូវផ្សព្វផ្សាយ ហើយពិបាករក ។ ឧ. ព័ត៌មានពីក្រុមហ៊ុន ការស្រាវជ្រាវ និងរបាយការណ៍ផ្សេងទៀត ។
8. ជាផ្នែកដែលនិយាយពីការថ្លែងអំណរគុណដល់អ្នកដែលបានជួយក្នុងដំណើរការរៀបចំនិងសរសេររបាយការណ៍ ។ អ្នកអាចសរសេរផ្នែកនេះនៅផ្នែកខាងដើមនៃរបាយការណ៍បន្ទាប់ពីទំព័រមាតិកា ។
9. ជាផ្នែកមួយដែលប្រាប់អ្នកអាននូវអ្វីដែលអ្នកនឹងនិយាយពីរបាយការណ៍នេះ ។ ផ្នែកនេះរួមមាន៖
   - លិខិតយល់ព្រមឬព្រមគ្នា
   - ឈ្មោះអ្នកស្នើសុំរបាយការណ៍
   - ឈ្មោះអ្នកសរសេរ ឬក្រុមមនុស្សដែលទទួលខុសត្រូវក្នុងការស្រាវជ្រាវ
   - គោលបំណង ឬហេតុផលសម្រាប់របាយការណ៍
   - សង្ខេបពីវិធីសាស្ត្រក្នុងការសាកសួរ
   - សង្ខេបពីសារគតទូទៅនៃប្រធានបទនេះគឺគ្រាន់តែជាប្រវត្តិសង្ខេបដែលអាចឲ្យអ្នកអានអាចតាមដានរបាយការណ៍នេះបាន ។ ឧ. អ្នកអាចបង្ហាញពីកាលៈទេសៈដែលអ្នកបានដឹកនាំធ្វើរបាយការណ៍នេះ ។
   - វាមិនមែនជាផ្នែកដែលនិយាយលំអិតទេ ។
10. ផ្នែកនេះប្រាប់ពីសៀវភៅដែលអ្នកប្រើប្រាស់ក្នុងការស្រាវជ្រាវ និងប្រភពនៃការបោះពុម្ពផ្សាយផ្សេងៗ

11. ផ្នែកនេះរួមមាន៖

- ចំណាងជើង (ចំណាងជើងរួមនៃរបាយការណ៍)
- ឈ្មោះអ្នកនិពន្ធ
- អ្នកទទួល អ្នកអាន
- កាលបរិច្ឆេទ
- លេខឯកសារយោង

**ចម្លើយ ចំណុច ខ**

1. J
2. K
3. H
4. B
5. E
6. F
7. D
8. G
9. I
10. C
11. A

ការតំរៀបតាមលំដាប់: A K G B I E H J C D F

## ផ្នែកទី៣: ការអនុវត្តសរសេរកំណត់ហេតុ

- សេចក្តីផ្តើម និងការបង្ហាញពីគោលបំណងនៃមេរៀន
- ការសំដែង និងការឡើងបង្ហាញ
- សំណួរបំផុសគំនិត
- ឆ្លុះបញ្ចាំងការសំដែង
- ការលំបាកនៅពេលធ្វើកំណត់ត្រា

## សេចក្តីផ្តើម

កំណត់ហេតុកិច្ចប្រជុំគឺជាប្រភពព័ត៌មានមួយក្នុងចំណោមប្រភពព័ត៌មានជាច្រើនទៀត ដែលអាចនឹងត្រូវបានគេដកស្រង់យកទៅបញ្ចូលក្នុងរបាយការណ៍អ្វីមួយ ឧទាហរណ៍ដូចជានៅក្នុងភាគណាមួយនៃរបាយការណ៍វិវឌ្ឍន៍ និងភាយតំលៃប្រាកដជានឹងត្រូវបានគេដកស្រង់ដាក់បញ្ចូលនូវព័ត៌មានមួយចំនួនស្តីអំពីសមិទ្ធផលដែលសម្រេចបានដែលកើតចេញពីការពិភាក្សាព្រមព្រៀងគ្នា នៅក្នុងអង្គប្រជុំនៃក្រុមវាយតំលៃ ។ ដោយយោងតាមហេតុផលនេះ ការធ្វើកំណត់ហេតុប្រជុំគឺរួមចំណែកមួយយ៉ាងសំខាន់ដល់ការសរសេររបាយការណ៍ ។

## គោលបំណងនៃមេរៀននេះ:

នៅចុងបញ្ចប់នៃមេរៀននេះ អ្នកចូលរួមនឹង:

- ទទួលបានចំណេះដឹងពីរបៀបសរសេរកំណត់ហេតុ
- មានបទពិសោធន៍ក្នុងការកត់ត្រាកំណត់ហេតុប្រជុំ

## ការសំដែង

សិក្ខាកាមម្នាក់ឡើងនិយាយពីបទពិសោធន៍ផ្ទាល់ខ្លួន ប្រវត្តិសង្ខេបនៃអង្គការដោយរួមបញ្ចូលនូវពេលវេលា គោលបំណង និងទីកន្លែង ហើយសិក្ខាមដទៃទៀតស្តាប់ ហើយកត់ត្រានូវចំណុចសំ-ខាន់ៗ ពីការសំដែងនេះ ។

## សំណួរបំផុសគំនិត

- តើអ្នកកត់ត្រាបានអ្វីខ្លះ?
- តើបញ្ហាអ្វីខ្លះដែលអ្នកជួបប្រទះនៅក្នុងការកត់ត្រា?
- តើអ្នកត្រូវការកត់ត្រានៅពេលណាខ្លះ?
- តើមានធាតុអ្វីខ្លះដើម្បីឲ្យការកត់ត្រារបស់អ្នកបានល្អ?
- តើយើងគួរមានគោលការណ៍ដូចម្តេចដើម្បីឲ្យការកត់ត្រាបានល្អ?

## ចម្លើយចូលរួម

ជាទូទៅយើងត្រូវកត់ត្រានៅពេលណាយើងត្រូវការសំភាស ទស្សនៈសិក្សា ការប្រជុំពិភាក្សា សិក្ខាសាលា និងពេលវាយតម្លៃបុគ្គលិកជាដើម ។

# កំណត់ត្រាល្អ

- ព័ត៌មានត្រូវឲ្យបានត្រឹមត្រូវ
- ត្រូវបញ្ចូលព័ត៌មានសំខាន់ៗកុំឲ្យលំអិតពេក និងខ្លីពេក
- បង្ហាញការរៀបចំគំនិតជាទូទៅឲ្យបានច្បាស់លាស់
- សរសេរឲ្យខ្លីហើយច្បាស់ គឺជាប្រើអក្សរកាត់ និងបច្ចេកទេសផ្សេងទៀតសម្រាប់ ពង្រួញព័ត៌មានឲ្យខ្លី
- ជួយឲ្យអ្នកអានងាយយល់ ឬចាប់បាននូវចំណុចសំខាន់ៗ
- អាចប្រើទៅថ្ងៃក្រោយប្រកបដោយប្រសិទ្ធភាព ។ ឧ. សម្រាប់របាយការណ៍
- រាប់បញ្ចូលទាំងចំណុចដែលយើងនឹងតាមដានខាងក្រោយ ។ ឧហ. យោបល់ខ្លួនឯងផ្សេងៗ ឬប្រតិកម្មលើគំនិតផ្សេងៗ

- កំណត់ត្រាល្អ យើងត្រូវចេះចាត់ចែងឲ្យបានសមស្រប ដោយមានវិធីសាស្ត្រពីរ៖
  - ➢ កត់ត្រាតាមលំដាប់លំដោយ យើងត្រូវកត់ត្រាប្រធានបទ រួចយកមកដាក់លេខរៀងតាម ខ្លឹមសារនីមួយៗ បន្ទាប់មកទៀតកត់ត្រាចំណុចសំខាន់ៗតាមលំដាប់លំដោយតៗគ្នា

    ឧ. ប្រធានបទ............

    ១....................................

    - ...........................
    - ...........................

២...........................................

- ...............................
- ................................

➢ គូរជាគំរូបំពេញ: រាល់ប្រធានបទ ឬខ្លឹមសារសំខាន់ៗនៃព័ត៌មាន យើងត្រូវកត់ត្រាគូរជាផែនទីគំនិត ជាប្រអប់ ឬជាកងខ្លឹងត្រី ។ល។ ឧ គំរូនៃការកត់ត្រាបែបជាប្រអប់ គំរូនៃការកត់ត្រាបែបជាតារាង គំរូនៃការកត់ត្រាបែបជារង្វង់

## ការណែនាំ: ការធ្វើកំណត់ហេតុនៃកិច្ចប្រជុំ

គោលបំណងនៃកំណត់ហេតុ គឺផ្តល់នូវឯកសារមួយសំខាន់អំពីការប្រជុំ ។តើអំពីអ្វី? ពេលណា? នរណាចូលរួមខ្លះ? តើអ្វីខ្លះដែលបានពិភាក្សា? តើព័ត៌មានអ្វីខ្លះដែលទទួលបាន? តើសម្រេចលើអ្វីខ្លះ ឬចំណុចសកម្មភាពណាដែលមានការឯកភាពគ្នា? ឯកសារនេះអាចត្រូវប្រើប្រាស់

- សំរាប់បង្ហាញលើការពិភាក្សាប្រជុំលើកក្រោយ
- សំរាប់ណែនាំ ឬបាំនស្មានការងាររបស់នរណាម្នាក់
- សំរាប់ប្រើភជាឯកសារយោងអំពីអ្វីដែលបានសម្រេចថាត្រូវធ្វើយ៉ាងណានិងអនុវត្តពេលណាឲ្យបាន ។

### គោលការណ៍

1. ត្រូវឲ្យប្រាកដថា អ្នកមានសម្ភារ:គ្រប់គ្រាន់ដើម្បី ដូចជា ក្រដាស ប៊ិចសម្រាប់ត្រៀម...
2. មុនពេលចាប់ផ្តើមប្រជុំអ្នកត្រូវប្រាកដថា អ្នកមានកំណត់ហេតុការប្រជុំលើកមុន និងរបៀបវារ:នៃការប្រជុំលើកនេះ បើពួគគេមាន ។
3. ធ្វើការកត់ត្រាឲ្យបានត្រឹមត្រូវអំពីឈ្មោះ ថ្ងៃទី ទីកន្លែងប្រជុំ ហើយអ្នកដែលចូលរួមប្រជុំ មុនពេលការប្រជុំចាប់ផ្តើម ។
4. នៅពេលប្រជុំចាប់ផ្តើមត្រូវព្យាយាមកត់ត្រាតាមផ្នែកនិមួយៗដែលមានក្នុងរបៀបវារ:
5. គេមិនចាំបាច់កត់ត្រានូវរាល់ចំណុចដែលគេគ្រប់គ្នានិយាយនោះទេ ។ ចំណុចពីរដែលសំខាន់ក្នុងការកត់ត្រាគឺ៖
    - សង្ខេបនូវសំណុចសំខាន់ៗដែលមាននៅក្នុងការពិភាក្សា
    - រាល់ការសម្រេចនានាដែលទទួលបាន ឬរាល់ចំណុចដែលមានការឯកភាពគ្នា

ទោះជាយ៉ាងណាក៏ដោយការកត់ត្រាកំណត់ហេតុជាជំនាញមួយដែលត្រូវប្រើពេលយូរដើម្បីធ្វើឲ្យបាន ហើយពលំបាកក្នុងការដឹងនូវអ្វីដែលសំខាន់នៅពេលការប្រជុំបានដំណើរការ ។ សម្រាប់អ្នក

ដែលពុំធ្លាប់ធ្វើកំណត់ហេតុវាងាយស្រួលសម្រាប់គេដោយកត់នូវអ្វីៗទាំងអស់ហើយធ្វើការសង្ខេប មុនពេលបញ្ចប់ ហើយចែកចាយ ។

6. បើសិនជានរណាម្នាក់នៅក្នុងអង្គប្រជុំបានផ្តល់ព័ត៌មានជាលាយល័ក្ខអក្សរ គឺយើងមិនត្រូវការកត់បញ្ចូលទាំងស្រុងនោះទេ ។ យកល្អជាការប្រពៃយើងគួរតែសួរទៅម្ចាស់ព័ត៌មានដើម្បីសុំគេមួយច្បាប់សម្រាប់ភ្ជាប់ និងអាចទុកវាប្រើសម្រាប់សង្ខេបនៅពេលក្រោយ ។
7. ពេលមានការសម្រេចលើអ្វីមួយឬការឯកភាពពីចំណុចណាមួយគួរតែកត់ត្រាឲ្យបានល័អិត ។ កំណត់ហេតុជាឯកសារមួយដែលនិយាយអំពីថា តើអ្នកណាយល់ព្រមធ្វើអ្វី? ហើយនៅពេលណា? ដែលការនេះជាទូទៅច្រើនមានសារៈសំខាន់ជាងការកត់ត្រាទុកអំពីអ្នកណានិយាយថាដូចម្តេចនោះ ។
8. ពេលខ្លះការពិភាក្សាក្នុងអង្គប្រជុំមានការកើន្តប្រឡូំលើខ្លឹមសារណាមួយ ហើយលំបាកនឹងដឹងថាសម្រេចដល់ណាហើយ វាមានផលប្រយោជន៍សម្រាប់គេគ្រប់គ្នាដោយអ្នកកត់ត្រាសួរបញ្ជាក់ឡើងវិញ ។ ដូចពេលខ្លះពួកគេមិនច្បាស់ខ្លួនឯងថាមកដល់ត្រឹមចំណុចនេះយ៉ាងណាទេ ។ វាក៏កើតឡើងផងដែរ នៅពេលខ្លះវាពុំមានការឯកភាពគ្នា អ្នកកត់ត្រាគួរសួរថា "តើអ្វីទៅដែលយើងគួរកត់ត្រាដាក់ក្នុងកំណត់ហេតុអំពីការពិភាក្សានេះ" ។ ធ្វើបែបនេះវាប្រសើរជាងឲ្យការពិភាក្សានៅតែមានការកើន្តប្រឡូំហើយអាចនាំឲ្យមានការធ្វើកំណត់ហេតុមួយដែលមានលក្ខណៈមិនច្បាស់លាស់ ។
9. ក្រោយពេលប្រជុំ ត្រូវចំណាយពេលរៀបចំបញ្ចប់នូវកំណត់ហេតុដោយវាយបញ្ចូលទៅក្នុងកុំព្យូទ័រឲ្យបានត្រឹមត្រូវនៅក្រោមចំណងជើងដែលមាននៅក្នុងរបៀបវារៈ ។ ចំពោះអ្នកដែលមិនធ្លាប់ធ្វើកំណត់ហេតុ ជាការល្អគួរសរសេរព្រាងមួយ ហើយសុំឲ្យនរណាម្នាក់ដែលចូលរួមប្រជុំពិនិត្យមើលកំណត់ហេតុនេះជាមុន ដើម្បីធានាបាននូវភាពត្រឹមត្រូវនៃព័ត៌មានដែលបានកត់ត្រាទុករួចមុននោះ មុនពេលដែលកំណត់ហេតុនេះត្រូវបានចែកផ្សាយទៅគ្រប់គ្នា។
10. ធ្វើយ៉ាងណាព្យាយាមធ្វើកំណត់ហេតុឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្រោយពីការប្រជុំចប់ថ្មីៗ ព្រោះអ្នកនូវចងចាំបានល្អនូវអ្វីៗដែលកត់ត្រាទុក ហើយប្រសិនបើមានចំណុចអ្វីផ្សេងៗដែលមិនច្បាស់ អ្នកផ្សេងៗទៀតក៏អាចជួយរំលឹកអ្នកបានដែរ ។

## គំរូនៃការធ្វើកំណត់ហេតុពេលប្រជុំ

ឈ្មោះអង្គប្រជុំ ........................................

ថ្ងៃខែ និងពេលកំណត់ ........................................

ទីកន្លែងប្រជុំ ........................................ អ្នកចូលរួម ........................................ ស្ត្រី..........................

ដំណើរការប្រជុំលើរបៀបវារៈ

1. ស្វាគមន៍អ្នកចូលរួម និងសុំអភ័យសម្រាប់អ្នកអវត្តមាន
2. កំណត់ហេតុនៃការប្រជុំលើកមុន
3. ចំណុចមួយចំនួនដែលត្រូវលើកឡើងបន្ត
    - រាយការណ៍អំពីសកម្មភាពដែលត្រូវអនុវត្តដែលបានព្រមព្រៀងគ្នានៅពេលប្រជុំលើកមុន
    - ព័ត៌មានថ្មីដែលបានចែករំលែកនៅពេលពិភាក្សាក្នុងអង្គប្រជុំលើកមុន
    - ការពិភាក្សាទាំងឡាយដែលពុំទាន់បានបញ្ចប់នៅពេលអង្គប្រជុំលើកមុន
4. បញ្ហាសំខាន់ៗសម្រាប់លើកមកពិភាក្សាក្នុងកិច្ចប្រជុំថ្ងៃនេះ
    - ................................
    - ................................
    - ................................
    - ................................
    - ................................
    - ................................
5. បញ្ហាផ្សេងៗបើមាន "អ្វីៗដែលត្រូវលើកឡើងក្នុងកិច្ចប្រជុំតែមិនមាននៅក្នុងរបៀបវារៈ"
6. កាលបរិច្ឆេទប្រជុំលើកក្រោយ

## ផ្នែកទី៤ ការសង្ខេបព័ត៌មាន

- សេចក្តីផ្តើម និងការបង្ហាញគោលបំណងមេរៀន
- ការបង្ហាញ
    - គោលការណ៍នៃការសង្ខេបព័ត៌មាន
    - ឧទាហរណ៍នៃការសង្ខេបព័ត៌មានសមស្រប និងមិនសមស្រប
- សំណួរបំផុសគំនិតអំពីហេតុផលក្នុងការសង្ខេបព័ត៌មាន
- ការពិភាក្សាអំពីការលំបាកពេលសង្ខេប
- លំហាត់ផ្ទាល់ខ្លួន និងជាក្រុម
- ការសង្ខេបមេរៀន

## សេចក្តីផ្តើម

ដើម្បីសរសេររបាយការណ៍មួយឲ្យបានល្អយើងត្រូវប្រមែប្រមូលព័ត៌មានឲ្យបានគ្រប់គ្រាន់ដែលក្នុងនោះព័ត៌មានខ្លះមានប្រយោជន៍ ហើយព័ត៌មានខ្លះទៀតមិនពាក់ព័ន្ធនឹងប្រធានបទទេ ។ ហេតុដូច្នេះហើយយើងត្រូវការសង្ខេបនូវព័ត៌មានទាំងនោះ ដើម្បីដាក់បញ្ចូលទៅក្នុងតួសេចក្តីនៃរបាយការណ៍។

## គោលបំណង

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមទាំងអស់នឹងទទួលបានៈ

- ចំណេះដឹងអំពីរបៀបនៃការសង្ខេបព័ត៌មាន
- បទពិសោធន៍នៃការសង្ខេបព័ត៌មាន

## គោលការណ៍នៃការសង្ខេបព័ត៌មាន

- ពិនិត្យមើលគោលការណ៍ ឬការណែនាំ
    - តើយើងសង្ខេបសម្រាប់នរណា?
    - តើទំរង់ណាដែលយើងគួរប្រើ?
    - តើអ្នកប្រើពាក្យបច្ចេកទេសដែរ ឬទេ?
    - តើផ្នែកនៃប្រធានបទមួយណាដែលយើងត្រូវការសង្ខេប? ទាំងអស់ ឬមួយផ្នែក?
- ការអានឯកសារ

- មុននឹងធ្វើការសង្ខេបព័ត៌មានណាមួយ អ្នកគួរតែចំណាយពេលអានយ៉ាងតិចពីរដង
- ការអាននេះវាអាចឲ្យអ្នកយល់យ៉ាងច្បាស់អំពីអត្ថន័យនៃឯកសារទាំងមូលមុននឹងអ្នកសង្ខេបវា

• កត់ចំណាំ និងកត់ត្រានូវពាក្យគន្លឹះ
- នៅពេលដែលអ្នកអាននូវព័ត៌មាននៃឯកសារនោះ អ្នកត្រូវកំណត់ពាក្យសំខាន់ៗនៃព័ត៌មាន មានន័យថាអ្វីជាចំណុចសំខាន់នៅក្នុងព័ត៌មាននោះ ដែលអ្នកអានគួរតែដឹង ។
- ធ្វើការពិនិត្យលើអត្ថបទទាំងមូល ហើយជ្រើសរើសពាក្យឬឃ្លាដែលផ្តល់នូវចំណុចៗសំខាន់ក្នុងព័ត៌មាន ឬក៏វិធីផ្សេងទៀត គឺអានអត្ថបទទាំងមូលដោយគូសលើពាក្យ ឬឃ្លាដែលពុំមានសារៈសំខាន់ចំពោះព័ត៌មាននោះ ។

• ពង្រាងការសង្ខេប
- ធ្វើការកត់ត្រានូវពាក្យឬឃ្លាសំខាន់ៗដែលអ្នកបានជ្រើសរើសរួចជាឯចំលងប្រយោគពីប្រភពដើម ។ បំណងក្នុងការសរសេរឯកសារនៃបែបបទនណាម្នាក់ វាមិនមែនមានការលំបាកតែមួយទេវានាំឲ្យការងារច្របូកច្របល់ ។
- ត្រូវផ្លាស់ប្តូរលំដាប់លំដោយសម្ភារៈ ប្រសិនបើអ្នកគិតថា វាមានលក្ខណៈសមហេតុសមផល
- ប្រសិនបើអ្នកមានពាក្យបច្ចេកទេស យកល្អអ្នកគួរសរុបរាល់ចំណុចទាំងអស់ដែលអ្នកគិតថាវាមានសារៈសំខាន់ ។ វាមានភាពងាយស្រួលក្នុងការកាត់បន្ថយចំនួនពាក្យជាងដាក់ព័ត៌មានបន្ថែម ។

• ពិនិត្យពង្រៀងសម្រាប់មាតិកា និងប្រវែងនៃអត្ថបទ: តើអ្នករៀបចំចាត់ចែងរាល់អ្វីៗទាំងអស់ដែលវាមានសារៈសំខាន់ក្នុងអត្ថបទហើយឬនៅ?

• អានឡើងវិញនូវពង្រាងដែលបានផ្លាស់ប្តូរ
- ពិនិត្យអត្ថបទឡើងវិញ
- គ្រប់ពាក្យបំពេញន័យឲ្យប្រយោគហើយឬនៅ
- តើការអានទៅវាស៊ីគ្នាទេនូវចំណុចនីមួយៗ
- ពិនិត្យលើអក្ខរាវិរុទ្ធ និងវិធីប្រើវណ្ណយុត្ត

• ព្រៀងឡើងវិញ និងសង្ខេបសំរេចចុងក្រោយ

## ឧទាហរណ៍៖

**<u>ការសង្ខេបព័ត៌មាន:</u>**

ដើម្បីផ្តល់ព័ត៌មានចាំបាច់និងត្រឹមត្រូវទៅដល់អ្នកអាន ជាបឋមអ្នកត្រូវមើលពីបញ្ហាដែលបានពីទស្សនវិស័យរបស់អ្នកអាននោះជាមុនសិន ។ បញ្ហាមួយគឺ ការត្អូញត្អែររបស់ប្រធានជារឿយៗនៅពេលគាត់បានទទួលរបាយការណ៍ដែលនិយាយមិនចំបញ្ហា បញ្ហាធំទូលាយពេក ឬក៏គ្មានបញ្ហាអ្វីទាំងអស់ ។ ដូច្នេះវិធីដែលប្រសើរដើម្បីលើកឡើងនូវបញ្ហាដែលត្រឹមត្រូវសម្រាប់អ្នកអាននោះ គឺការរៀបឃ្លាជាទំរង់សំណួរដែលអាចចោទឡើងក្នុងគំនិតរបស់អ្នកអាន ។

**ការសង្ខេបមិនទាន់ល្អ** ដើម្បីផ្តល់ព័ត៌មានល្អទៅអ្នកអាន ជាបឋមអ្នកត្រូវមើលបញ្ហាដែលបានពីទស្សនវិស័យរបស់ពួកគេ ។ ជាញឹកញាប់ប្រធានតែងតែមិនពេញចិត្តនឹងរបាយការណ៍ដែលមិនពាក់ព័ន្ធ មិនចំបញ្ហាឬគ្មានបញ្ហាតែម្តង ។

<u>ពីព្រោះ</u>

- ឃ្លាទាំងនោះហាក់ដូចជាមិនទាន់មានទំនាក់ទំនងល្អនឹងគ្នា
- បាត់បង់អត្ថន័យសំខាន់ៗខ្លះ ពោលគឺសំណើសម្រាប់ទង្វើដែលល្អជាងនេះ ។ វិធីដែលប្រសើរដើម្បី លើកឡើង.......................

**ការសង្ខេបសមរម្យ**

ប្រធានតែងតែរអ៊ូរទាំថា របាយការណ៍ដែលគាត់បានទទួលគឺមិនទាក់ទងនឹងបញ្ហារៀងរ៉ាវជាសំខាន់ ។ ដូច្នេះអ្នកគួរគិតថាតើសំណួរអ្វីខ្លះដែលអ្នកអានអាចសួរ និងផ្តល់ព័ត៌មានដែលពាក់ព័ន្ធ ។

## សំណួរពិភាក្សា

- ហេតុអ្វីបានជាយើងត្រូវសង្ខេបព័ត៌មាន?
- តើពីមុនមកអ្នកធ្លាប់មានបទពិសោធន៍ក្នុងការសង្ខេបព័ត៌មាន នៅពេលសរសេរឯកសារណាមួយដែរឬទេ?
- តើអ្នកប្រើប្រាស់ដំណើរការណាខ្លះក្នុងការសង្ខេបព័ត៌មានទាំងនោះ? ចូររៀបរាប់?
- តើអ្នកជួបការលំបាកអ្វីខ្លះក្នុងការសង្ខេបព័ត៌មាននៅពេលសរសេរឯកសារនានា?

**ចម្លើយចូលរួម**

- វាប្រើពេលវេលាយូរក្នុងការសរសេរនូវអ្វីៗគ្រប់បែបយ៉ាង
- ព័ត៌មានខ្លះពុំមានការពាក់ព័ន្ធទាំងអស់ទៅនឹងគោលបំណងនៃឯកសារទេ
- អ្នកអានមិនត្រូវការព័ត៌មានលំអិតពេកទេ គឺចង់បានតែចំណុចសំខាន់ៗ
- វាធ្វើឲ្យអ្នកអានមានការធុញទ្រាន់ក្នុងការអាននូវអ្វីៗទាំងអស់ដែលពុំចាំបាច់
- ព័ត៌មានខ្លះមិនស៊ីជម្រៅ ហើយខ្លះទៀតមិនពាក់ព័ន្ធទៅនឹងគោលបំណង
- វាមានភាពងាយស្រួលក្នុងការអាន
- ការលំអិតពេកអាចនាំឲ្យមានការភ័ន្តច្រឡំ
- អ្នកអានប្រហែលជាពុំអាចដឹង អំពីអ្វីៗដែលអ្នកសរសេរគិតថាជាចំណុចសំខាន់ឡើយ
- បើមិនសង្ខេបទេ នោះយើងនឹងចំណាយពេលច្រើនក្នុងការអាន ឬនាំឲ្យខាតពេល
- វានឹងបង្ហាញច្បាស់អំពីអ្វី ដែលអ្នកសរសេរបានគិតលើសារដែលត្រៀមផ្ញើទៅអ្នកអាន

## លំហាត់អនុវត្ត១

**ការណែនាំ: នៅក្នុងកថាខ័ណ្ឌទាំងពីរខាងក្រោម ចូរសង្ខេបឲ្យនៅត្រឹម១ភាគ៣នៃអត្ថបទទាំងមូល។**

**សង្ខេបព័ត៌មាន**

ក. ឧបសគ្គនៃការប្រាស្រ័យទាក់ទងមានពីរ គឺឧបសគ្គខាងក្រៅពាក់ព័ន្ធនឹងឥទ្ធិពលខាងក្រៅ រួមមានសំលេងរំខាន ភាសាដែលប្រើប្រាស់ និងបរិយាកាសទូទៅ ។ ឧបសគ្គខាងក្នុងបានកើតឡើងចំពោះអ្នកទទួលមានឥរិយាបថ ដោយផ្អែកទៅលើបទពិសោធន៍ពីអារម្មណ៍ ការរំភើប និងដំណើរនៃការគិតដោយទាក់ទងនឹងអ្នកប្រាស្រ័យទាក់ទងនឹងខ្លឹមសារនៃសារ ។ កត្តាទាំងអស់នេះមានឥទ្ធិពលទៅលើការទទួលយករបស់អ្នកទទួល ។

ខ. ជាញឹកញាប់វាមិនងាយស្រួលក្នុងការចូលរួមក្នុងវគ្គសិក្ខាសាលាប្រកបដោយថាមពលពេញលេញ និងការសប្បាយរីករាយនោះទេ ។ ក្រុមខ្លះមានការលំបាកជាងក្រុមដទៃទៀត ជួនកាលគ្រូបណ្តុះបណ្តាលមានការបារម្ភផ្ទាល់ខ្លួនដូចជា ឈឺថ្កាត់ឬការគាប់សង្កត់ពីការងារទាំងឡាយដែលក្រៅពីការងារបណ្តុះបណ្តាល ។ ប៉ុន្តែគ្រូបណ្តុះបណ្តាលត្រូវតែជំនះនូវអាកប្បកិរិយាអវិជ្ជមានទាំងនេះ ។ សិក្ខាកាមដែលខ្វះការលើកទឹកចិត្ត និងសង្កេតយ៉ាងហ័សនូវអារម្មណ៍របស់គ្រូបណ្តុះបណ្តាល និងឆ្លៀតយកឱកាសដើម្បីសំដែងភាពមិនសមរម្យ ។ ឧទាហរណ៍ នាំគ្នាជជែករឿងផ្សេងៗក្រៅពីវគ្គបណ្តុះបណ្តាល នៅពេលដែលសិក្ខាកាមខ្លះទៀតចង់រៀនបានស្រួល ពីព្រោះអ្នកសម្របសម្រួលហាក់ដូចជាមិនចាប់អារម្មណ៍ ។

**ចម្លើយចូលរួម**

ក. ការទទួលយករបស់អ្នកទទួលស្ថិតក្រោមឥទ្ធិពលពីរយ៉ាងគឺកត្តាដែលជាឧបសគ្គខាងក្រៅដូចជាសំលេង បរិយាកាស និងកត្តាខាងក្នុងមានអារម្មណ៍ និងបទពិសោធន៍កន្លងមក ។

ខ. កត្តាខាងក្រៅអាចបណ្តាលមកពីអ្នកសំរបសំរួលមានឥរិយាបថជាអវិជ្ជមាននៅក្នុងពេលសិក្សា ។ បើសិនជាពួកគេមិនបំបាត់នូវបញ្ហាទាំងនេះទេ សិស្សទាំងឡាយពុំមានការលើកទឹកចិត្តហើយសំដែងនូវអាកប្បកិរិយាមិនសមរម្យ ឯសិស្សដែលមានទឹកចិត្តរៀននឹងពុំអាចរៀនបានឡើយ ។

## លំហាត់អនុវត្ត២ សង្ខេបព័ត៌មានខាងក្រោម

<u>ការិយាល័យរបស់អង្គការមួយ</u>

យើងដឹងហើយថា សំរាប់អង្គការមិនមែនរដ្ឋាភិបាលធំៗតែងតែមានការិយាល័យស្អាតៗ ។ នាយករបស់គេនិយាយថា ការិយាល័យគឺជាកន្លែងដំបូងបំផុតដែលគេអាចយល់ដឹងពីអង្គការ ដូច្នេះការិយាល័យត្រូវតែរៀបចំឲ្យបានស្អាតបាត និងមានការទាក់ទាញ ។ ការិយាល័យស្ថិតនៅកណ្តាលទីក្រុង ដែលមានអង្គការជាច្រើនមានការិយាល័យនៅទីនោះ អ្នកខ្លះហៅថាជាតំបន់របស់អង្គការមិនមែនរដ្ឋាភិបាល ដែលមានន័យថាមានចំងាយល្មមក្នុងការចូលរួមប្រជុំជាមួយសហការីដែលមកពីស្ថាប័នផ្សេងទៀត ហើយក៏មានក្រសួងជាច្រើនក៏នៅក្បែរនោះដែរ។

អគារនេះជាភូមិគ្រឹះដ៏ទំនើបដែលពីមុនមកជាផ្ទះរបស់ឯកជន ប៉ុន្តែម្ចាស់ផ្ទះដឹងថាគេអាចទទួលកំរៃជាច្រើនបន្ថែមក្នុងការជួលការិយាល័យ ជាជាងជួលទៅឲ្យគ្រួសារឯកជនណាដែលមានលទ្ធភាពជួលផ្ទះទាំងនោះ គឺមានន័យថាគេពិតជាអាចទិញផ្ទះទាំងនោះបាន ។ ផ្ទះនោះស្ថិតនៅក្នុងបរិវេណដែលមានសួនច្បារតូចមួយមានដើមឈើល្អៗ ។ ជាន់ទីទៅជាន់ក្រោមច្រើនប្រើសម្រាប់ចតរថយន្ត និងម៉ូតូ ។ ការទៅរកកន្លែងទទួលភ្ញៀវគឺគ្រាន់តែឡើងកាំជណ្តើរតែបីកាំប៉ុណ្ណោះ ដែលជាកន្លែងចាប់អារម្មណ៍ពីព្រោះកំរាលឥដ្ឋក្រាលដោយថ្មម៉ាប មានកៅអីល្អសម្រាប់ឲ្យភ្ញៀវអង្គុយស្រួល និងមានកូនដើមត្នោតតូចៗ ដោយមានរូបភាពអង្គរវត្តព្យួរនៅជាប់ជញ្ជាំង ។ ភាគច្រើនជាន់ក្រោម គឺប្រើសម្រាប់ការិយាល័យបុគ្គលិករដ្ឋបាល ។ អ្នកគ្រប់គ្រងផ្នែករដ្ឋបាលមានការិយាល័យមួយដោយឡែក ប៉ុន្តែបុគ្គលិកទាំងអស់គេមានការិយាល័យរួមធំមួយជាមួយគ្នា ។

ជាន់មួយទៀតគឺជាបន្ទប់ដ៏ធំដែលអាចប្រើសម្រាប់ប្រជុំបុគ្គលិក ។ល។ ប្រធានហិរញ្ញវត្ថុមានការិយាល័យនៅទីនោះដែលអាចមានសុវត្ថិភាពក្នុងការទុកដាក់លុយកាក់ និងឯកសារផ្សេងៗរបស់គាត់ ។ ផ្នែកហិរញ្ញវត្ថុនៅខាងមុខជាប់នឹងការិយាល័យរបស់ប្រធានហិរញ្ញវត្ថុ ដូចអាគាររដ្ឋបាលដែរគឺស្ថិតក្នុងបន្ទប់ធំតែមួយ ។ ការិយាល័យរបស់នាយកកម្មវិធីក៏នៅជាន់នេះដែរ ជាបន្ទប់ធំទូលាយល្អស្រួលព្រោះការប្រជុំច្រើនធ្វើនៅទីនេះ ។

នៅជាន់ទី២ ជាកន្លែងសម្រាប់បុគ្គលិកកម្មវិធីទាំងអស់ធ្វើការ ។ ការិយាល័យនេះ មានទំហំខុសៗ គ្នា ។ ការិយាល័យនីមួយៗមានបន្ទប់ទឹកដោយខ្លួនពីគ្នា ។ បណ្ណាល័យមានសៀវភៅ រីដេអូ របាយការណ៍ សៀវភៅសម្រាប់បណ្តុះបណ្តាលបានរៀបទៅតាមកម្មវិធីនីមួយៗ ហើយមានប្រយោជន៍សម្រាប់គេទាំងនោះ ។ ដោយសារថាគេត្រូវការប្រើប្រាស់ច្រើន តែពេលខ្លះដោយមានការខ្ចីខានពីអ្នកខ្លះមកពីអង្គការខាងក្រៅដែលត្រូវការប្រើប្រាស់របស់ទាំងនោះ ។ ក្រៅពីបញ្ហាទាំងនេះគឺម្នាក់ៗគឺសប្បាយចិត្តណាស់ហើយពួកគេគិតថា វាជាកន្លែងដ៏ល្អមួយសំរាប់ការិយាល័យធ្វើការងារ ។

**ចម្លើយចូលរួម: ការសង្ខេបព័ត៌មាន**

ការិយាល័យរបស់អង្គការធំៗ ជាភូមិគ្រឹះដំទំនើបសង់ឡើងក្នុងបរិវេណមួយ ដែលស្ថិតនៅក្នុងតំបន់មួយជាតំបន់របស់អង្គការមិនមែនរដ្ឋាភិបាល ។ នៅខាងក្រៅភូមិគ្រឹះមានសួនច្បារតូចមួយ និងចំណតរថយន្ត ។ នៅជាន់ក្រោមមានបន្ទប់ទទួលភ្ញៀវ ការិយាល័យរដ្ឋបាល បន្ទប់របស់អ្នកគ្រប់គ្រងផ្នែករដ្ឋបាល និងបន្ទប់ផ្សេងៗទៀតសម្រាប់បុគ្គលិករដ្ឋបាល ។ នៅជាន់បន្ទាប់មានការិយាល័យរបស់នាយក និងប្រធានហិរញ្ញវត្ថុ ហើយក៏មានការិយាល័យហិរញ្ញវត្ថុ និងសាលប្រជុំនៅទីនោះផងដែរ ។ ការិយាល័យសម្រាប់ក្រុមកម្មវិធី និងបណ្ណាល័យស្ថិតនៅជាន់ទៅបីជាមួយគ្នា ។

## ផ្នែកទី៥: ការសរសេរសេចក្តីផ្តើម និងការសន្និដ្ឋាន

- សេចក្តីផ្តើម និងការបង្ហាញគោលបំណងនៃមេរៀន
- ការងារក្រុមតូច: ជ្រើសរើសកថាខ័ណ្ឌដែលជាសេចក្តីផ្តើមនៃរបាយការណ៍
- ការងារក្រុមធំ: ឆ្លុះបញ្ចាំងលើការធ្វើលំហាត់ខាងលើ
- ការងារក្រុមធំ: គោលការណ៍ណែនាំក្នុងការសរសេរសេចក្តីផ្តើមនៃរបាយការណ៍
- ពិភាក្សាក្រុមតូច: ជ្រើសរើសកថាខ័ណ្ឌដែលជាសេចក្តីសន្និដ្ឋាន
    - លំហាត់សរសេរការសន្និដ្ឋាន
- ការងារក្រុមធំ: ការលំបាកក្នុងការសរសេររបាយការណ៍
    - ភាពខុសគ្នារវាងការសង្ខេបនិងការសន្និដ្ឋាន
- ការងារក្រុមធំ: គោលការណ៍ណែនាំអំពីការសរសេរសេចក្តីសន្និដ្ឋាន

### សេចក្តីផ្តើម

យើងបានសិក្សាអំពីរបៀបកត់ត្រាហើយយើងបានធ្វើការអនុវត្តនៅក្នុងថ្នាក់ ។ នៅក្នុងផ្នែកនេះ យើងនឹងសិក្សាអំពីរបៀបសរសេរសេចក្តីផ្តើម និងការសន្និដ្ឋាននៃរបាយការណ៍ ។ ម្យ៉ាងទៀតអ្នកនឹងមានឱកាសអនុវត្តការសរសេរសេចក្តីផ្តើម និងការសន្និដ្ឋាននៅក្នុងផ្នែកនេះទៀតផង ។

### គោលបំណង

នៅចុងបញ្ចប់នៃមេរៀននេះ អ្នកចូលរួមទាំងអស់នឹង៖

- បានកំណត់អំពីគោលការណ៍ណែនាំក្នុងការសរសេរសេចក្តីផ្តើម និងការសន្និដ្ឋាន
- បានអនុវត្តសរសេរសេចក្តីផ្តើម និងការសន្និដ្ឋានក្នុងការសរសេររបាយការណ៍

### ការពិភាក្សា

ការណែនាំ: អានកថាខ័ណ្ឌដែលជាសេចក្តីផ្តើមនៃរបាយការណ៍ ហើយធ្វើការជ្រើសរើសថាតើកថាខ័ណ្ឌណាមួយដែលលោកអ្នកគិតថាសមស្របជាងគេ ។ បន្ទាប់មកធ្វើការប្រៀបធៀបចំលើយរបស់ក្រុមអ្នកទៅនឹងក្រុមដទៃទៀត ។

១ក: អ្នកស្រីវីទីនី បានបំរើឲ្យអង្គការយើងអស់រយៈពេលប្រាំបីឆ្នាំហើយ ។ គេទាំងអស់គ្នាបានដឹងថាគាត់ជានាយកផ្នែកយុទ្ធនាការ ទោះបីភាជាលទ្ធផលនៃការតែងតាំងឡើងនាពេលថ្មីៗនេះក៏ដោយ ។ គាត់ជាអ្នករៀបចំធ្វើផែនការនិងចាត់ចែងយ៉ាងល្អប្រសើរបំផុត ហើយជាពិសេសគាត់បានទទួលជ័យជំនះនៅក្នុងយុទ្ធនាការដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយតាមកាសែត និងទូរទស្សន៍ ។

១ខ. អង្គប្រជុំអំពីយុទ្ធនាការ HIV បានប្រារព្ធឡើងនៅថ្ងៃទី២៣ ខែ០១ ឆ្នាំ២០១២ ។ វត្តមាននៅទីនោះមានលោក សំអុល អ្នកស្រី វីទីនី កញ្ញា បូព៉ានី លោក កែវ យ៉ាណូ និងលោក អ៊ឹម សាម៉េត ។ គោលបំណងនៃការប្រជុំនេះគឺដើម្បីពិភាក្សាអំពីផែនការផ្សេងៗដែលរៀបចំឡើងដោយនាយកយុទ្ធនាការដែលចាប់ផ្តើមឡើងនៅក្នុងកម្មវិធីយល់ដឹងអំពី HIV នៅពេលខាងមុខ ។

១គ. កម្មវិធីយល់ដឹងអំពី HIV របស់ពួកយើងនឹងចាប់ផ្តើមដំណើរការនៅឆ្នាំ២០១២ ហើយបុគ្គលិកម្នាក់ៗដែលពាក់ព័ន្ធនឹងយុទ្ធនាការនេះមានការរំភើប និងអបអរសាទរអំពីលទ្ធផលនៃសិក្ខាសាលាដែលបានរៀបចំសម្រាប់ក្រុមគោលដៅចំនួន១២ខេត្ត ដែលបានកំណត់នៅក្នុងអង្គប្រជុំអំពីការធ្វើផែនការយុទ្ធសាស្ត្រកាលពីខែមុន ។ យើងមានយុទ្ធនាការស្រដៀងគ្នានេះដែរកាលពីអតីតកាលដែលពួកគេធ្វើ ជាពិសេសក្នុងចំណោមក្មេងដែលមានវ័យជំទង់ ដើម្បីលើកទឹកចិត្តពួកគេឲ្យការពារជំងឺនេះជាជាងការព្យាបាល ។

**ផ្នែកផ្សេងៗនៃរបាយការណ៍**

២. ផែនការយុទ្ធសាស្ត្ររបស់អ្នកស្រី វីទីនី ត្រូវបានរៀបចំឡើងដោយមានជម្រើសពីរ ។ ទី១ គឺយុទ្ធសាស្ត្រការងារនេះធ្វើឡើងដោយការបិទក្រដាសដើម្បីផ្សព្វផ្សាយ ។ ទី២គឺការផ្សព្វផ្សាយតាមរយៈទូរទស្សន៍ ។ ជម្រើសទី២នេះត្រូវបានរៀបចំឡើងទៅតាមទស្សនៈរបស់ទស្សនិកជន ហើយព័ត៌មានអាចអាចទៅដល់ជនភាគច្រើនដែលគេនិយមមើលកម្មវិធីផ្សេងៗនៅក្នុងទូរទស្សន៍ ទោះបីជាគេមិនចង់មើលកម្មវិធី HIV ក៏ដោយ ហើយម្យ៉ាងទៀតការផ្សព្វផ្សាយបែបនេះ បង្កលទ្ធភាពឲ្យតំបន់ផ្សេងទៀតនៅក្នុងសហគមន៍អាចទទួលបានព័ត៌មានអំពីយុទ្ធនាការនេះ ។

៣. នៅពេលរំលឹកឡើងវិញនូវគ្រប់ផ្នែកទាំងអស់ ដូចជា គុណសម្បត្តិ និងប្រសិទ្ធភាពនៃជម្រើសនីមួយៗព្រមទាំងការចំណាយផ្សេងៗដូច្នេះគេក៏បានសម្រេចយកជម្រើសទី២ ។ ទូរទស្សន៍ត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយថាជម្រើសមួយដែលមានប្រសិទ្ធភាពជាងគេក្នុងការផ្សព្វផ្សាយព័ត៌មាននេះ ព្រោះ HIV ជាបញ្ហាជំងឺអង្វែងដែលយើងចាំបាច់ត្រូវតែស្វែងរកដំណោះស្រាយ ។

## ការពិភាក្សាតាមក្រុម

ឆ្លុះបញ្ចាំងការឆ្លើយបំហាត់ខាងលើ  អំពីហេតុផលដែលអ្នកជ្រើសរើសយកកថាខ័ណ្ឌដែលសមស្រប សម្រាប់អ្នក (ហេតុអ្វីបានជាអ្នកគិតថាវាសមស្រប?)

តើមានគោលការណ៍អ្វីខ្លះសម្រាប់សរសេរសេចក្តីផ្តើមនៃរបាយការណ៍?

**ចម្លើយចូលរួម**

## គោលការណ៍ណែនាំអំពីការសរសេរសេចក្តីផ្តើមនៃរបាយការណ៍:

1. សេចក្តីផ្តើមគឺជាផ្នែកដំបូងនៃរបាយការណ៍ ។ វាបង្ហាញពីប្រធានបទនិងគោលបំណងនៃរបាយការណ៍ ។នៅក្នុងផ្នែកនេះសរសេរជាទំរង់ប្រយោគដែលបង្ហាញពីប្រធានបទ ។
2. គួរមានបញ្ចូលនូវសេចក្តីថ្លែងការណ៍ទូទៅមួយ  ឬប្រយោគដែលផ្តល់ព័ត៌មានអំពីជីវប្រវត្តិសង្ខេបទូទៅទាក់ទងនឹងប្រធានបទនៃរបាយការណ៍
3. ព័ត៌មានដែលជួយគាំទ្រគំនិត  ឬគំនិតដែលត្រូវបានគេបញ្ចូលទៅក្នុងរបាយការណ៍គួរត្រូវបានគេសរសេរជាទំរង់ប្រយោគគាំទ្រទាំងឡាយដែលមានរូបរាងជាគម្រោង  ឬទំរង់នៃមាតិការបស់ផ្នែកដែលនៅសេសសល់នៃរបាយការណ៍ ។

ឧទាហរណ៍: គោលបំណងនៃរបាយការណ៍នេះគឺវាយតំលៃការបំពេញការងាររបស់លោក សាម៉េត ក្នុងរយៈពេលសាកល្បងបីខែក្នុងមុខដំណែងថ្មីជាអ្នកគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ ។ លោក សាម៉េតបានចូលបម្រើការងារឲ្យអង្គការអស់រយៈពេល៥ឆ្នាំនៅក្នុងផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុតាំងពីឆ្នាំ២០០៤ ហើយគាត់បានអភិវឌ្ឍជំនាញនៃការប្រាស្រ័យទាក់ទងក្នុងផ្នែករបស់គាត់  និងផ្នែកផ្សេងៗទៀតនៅក្នុងអង្គការ ។ លើសពីនេះទៀត គាត់ក៏បានអភិវឌ្ឍជំនាញផ្នែកគណនេយ្យ និងការសរសេររបាយការណ៍ ផងដែរ ។

## សំណួរ

- តើអ្នកមានការលំបាកអ្វីខ្លះនៅក្នុងការសរសេរសេចក្តីសន្និដ្ឋាន ។
- តើការសន្និដ្ឋានខុសពីការសង្ខេបដូចម្តេចខ្លះ?
- តើអ្នកត្រូវគិតពិចារណាលើចំណុចអ្វីខ្លះនៅពេលសរសេរសេចក្តីសន្និដ្ឋាន?

ចំលើយចូលរួម

| ភាពខុសគ្នារវាងការសង្ខេប និងការសន្និដ្ឋាន | |
|---|---|
| ការសង្ខេប | ការសន្និដ្ឋាន |
| និយមន័យ | |
| គឺជាការពិពណ៌នារៀបរាប់បែបខ្លីហើយមានន័យច្បាស់លាស់ងាយយល់អំពីរឿងអ្វីមួយ | គឺជាការសំរេចចិត្តក្នុងការបញ្ចេញជាមតិគំនិតយោបល់ ឬសំណើបែបជាអនុសាសន៍អំពីរឿងអ្វីមួយបន្ទាប់ពីបានពិនិត្យពិចារណាលើរាល់គ្រប់ព័ត៌មានទាំងអស់រួចមក ។ |
| គោលបំណង | |
| • ដើម្បីនិយាយឡើងវិញ ឬរំលេចឲ្យឃើញពីចំណុចសំខាន់នៃអ្វីមួយ ។<br>• ដើម្បីជួយសន្សំពេលវេលាដល់អ្នកអាន ដែលរវល់ច្រើន ដើម្បីច្រោះចេញនូវព័ត៌មានដែលមិនសំខាន់ ឬមិនចាំបាច់<br>• ដើម្បីធ្វើឲ្យអ្នកអានចាប់អារម្មណ៍<br>• ដើម្បីបង្ហាញពីខ្លឹមសារអ្វីមួយដែលអ្នកសរសេរចង់ឲ្យអ្នកអានដឹង ។ | • ដើម្បីបញ្ចប់អត្ថបទ ឬរបាយការណ៍<br>• ដើម្បីចែករំលែក ឬលើកជាសំណើរ ឬក៏ជាអនុសាសន៍ចំពោះអ្នកអានដែលជា លទ្ធផលនៃការសិក្សាស្វែងយល់ពីហេតុផលផ្សេងៗនៃព័ត៌មានរួចមក ។ |

## គោលការណ៍ណែនាំអំពីការសរសេរសេចក្តីសន្និដ្ឋាន

- ❖ ផ្នែកសន្និដ្ឋានរបស់ឯកសារជាការសង្ខេបគ្រួសៗនៃគ្រប់ចំណុចសំខាន់ៗទាំងអស់ដែលមានក្នុងតួចសេចក្តីរបស់អត្ថបទ ។ គោលបំណងរបស់ការសន្និដ្ឋានគឺជាការនិយាយអំពីឯកសារឡើងវិញ ដោយសង្ខេបលើគ្រប់ចំណុចសំខាន់ៗដែលបានបង្ហាញក្នុងតួរបស់អត្ថបទ ។ វាអាចមានផលប្រយោជន៍ចំពោះអ្នកដែលមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីអានឯកសារទាំងមូល តែគេចង់ដឹងចំណុចសំខាន់ៗដែលមានក្នុងនោះ ។
- ❖ សេចក្តីសន្និដ្ឋាន មិនគួរបញ្ចូលព័ត៌មានណាដែលថ្មីផ្សេងទៀតឡើយ ។
- ❖ ពុំមានបទដ្ឋានអំពីប្រវែង ឬទំហំរបស់សេចក្តីសន្និដ្ឋានឡើយ ។ ទំហំរបស់សេចក្តីសន្និដ្ឋាននិងបរិមាណនៃព័ត៌មាន ដែលគួរបញ្ចូលក្នុងសេចក្តីសន្និដ្ឋានគឺអាស្រ័យទៅតាមទំហំរបស់ឯកសារ ។ ផ្នែកទាំងពីរនេះគួរតែមានសមាមាត្រសមស្របទៅវិញទៅមក ហើយសេចក្តីសន្និដ្ឋានត្រូវតែខ្លីជាងច្រើនដងនៃតួអត្ថបទដើម ។

- ដំណើរការដ៏មានប្រយោជន៍ក្នុងការចងក្រងសេចក្តីសន្និដ្ឋានគឺជាការអានឡើងវិញលើឯកសារទាំងមូល ហើយកត់សម្គាល់ចំណុចសំខាន់ៗដែលបានបង្ហាញក្នុងតួសេចក្តីរបស់អត្ថបទ ។ ចំណុចទាំងនេះបានបង្ហាញត្រួសៗក្នុងទំរង់សេចក្តីសង្ខេប និងសេចក្តីសន្និដ្ឋាន ។ ចំពោះអ្នកដែលចង់ដឹង ព័ត៌មានលំអិតគេអាចត្រឡប់ទៅមើលផ្នែកសំខាន់ៗរបស់អត្ថបទវិញ ។
- ជារឿយៗរបាយការណ៍ត្រូវមានអនុសាសន៍របស់អ្នកសរសេរ ។ ប្រសិនបើរបាយការណ៍មានទំហំធំហើយត្រឹមត្រូវ ដូចជារបាយការណ៍វាយតំលៃជាដើម នោះអនុសាសន៍គួរត្រូវបានបញ្ចូលទៅក្នុងតួរបស់អត្ថបទ ។ ប្រសិនបើរបាយការណ៍ណាជារបាយការណ៍សង្ខេប នោះអនុសាសន៍គួរតែបញ្ចូលក្នុងសេចក្តីសន្និដ្ឋាន ហើយការបង្ហាញព័ត៌មានគាំទ្រក៏គួរបញ្ចូលដែរ ។